ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២២ និងទិសដៅការងារខែមករា ឆ្នាំ២០២៣

នៅក្នុងខែធ្នូនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១-មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៩ នីតិកាលទី៤ ចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

៣.១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មនៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន

៣.២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក)នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣.៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

-បានរៀបចំចាត់ចែងជូនគណៈកម្មការទី២ និងទី៩ ព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

-បានរៀបចំជូនសមាជិកព្រឹទ្ធសភា ប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លើសេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា

-បានរៀបចំជូនសមាជិកព្រឹទ្ធសភា ប្រជុំពិគ្រោះយោបល់ស្តីពី ការបង្កើតគណៈកម្មការពិសេស និងនីតិវិធីការងារ ដើម្បីរៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

**២-មុខងារតាមដានការអនុវត្តច្បាប់**

-បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការប្រមូលព័ត៌មាន ការផ្សព្វផ្សាយច្បាប់ ព្រមទាំងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

+អញ្ជើញទស្សនកិច្ចច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងស្ពានមិត្តភាពកម្ពុជា-ថៃ ច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ នៅខេត្តបន្ទាយមានជ័យ

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ អន្តោប្រវេសន៍ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីការងារ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍលើវិស័យនានារបស់ខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ លទ្ធផលនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ វឌ្ឍនភាព និងបញ្ហាប្រឈមនានា នៃការអភិវឌ្ឍមូលដ្ឋាន នៅខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

**៣-មុខងារតំណាង**

**-បានរៀបចំចាត់ចែង ផ្តល់សេវា និងអមដំណើរ៖**

**+សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងប្រជាពលរដ្ឋ នៅខេត្តព្រះសីហនុ

**+ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា៖**

• អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍

លើកទី៤៤ នៃទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា (២ធ្នូ ១៩៧៨ -២ធ្នូ ២០២២) នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ

- អញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការទូទាំងខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ជាតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តព្រែកជ្រៃ ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ
- អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធកុដិ និងសមិទ្ធផលនានា ក្នុងវត្តតាំងក្រសាំងខាងជើង ស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **អំ សុខ** ញោមបង្កើតរបស់សម្តេចព្រះពោធិវ័ង្ស កិត្តិបណ្ឌិត **អំ លីមហេង** សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា

+គណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាលជាមួយសិស្សានុសិស្សក្រីក្រមកពីវិទ្យាល័យត្បែង និងវិទ្យាល័យទួលក្បិល ដែលនឹងត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិ នៅខេត្តកំពង់ធំ និងចូលរួមអបអរសាទរពិធីប្រកាសខេត្តត្បូងឃ្មុំ អស់មីន

+ឯកឧត្តមប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចូលរួមសិក្ខាសាលាស្តីពី កិច្ចសន្ទនាអន្តរជំនឿសាសនា ដើម្បីសុខដុមនីយកម្មសាសនានៅកម្ពុជាឆ្នាំ២០២២ ក្រោមប្រធានបទ "សាសនិកចូលរួមប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប"

+ឯកឧត្តមអនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញទទួលអំណោយសប្បុរសធម៌ពីព្រះអនុគណខណ្ឌដង្កោ រាជធានីភ្នំពេញ ជូនយុវជន យុវនារី រងគ្រោះដោយសារគ្រឿងញៀន

+លោកជំទាវប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយរបស់ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ចែកជូនដល់ក្មួយៗពិការភាពសតិបញ្ញា និងអូទីស្សឹម នៅខេត្តកណ្តាល

+ឯកឧត្តមប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា៖

- អញ្ជើញនាំយកអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ទៅប្រគល់ជូនរដ្ឋបាលខេត្ត និងមន្ទីរពេទ្យបង្អែក នៅខេត្តពោធិ៍សាត់ និងមន្ត្រីសុខាភិបាល នៅខេត្តបន្ទាយមានជ័យ

• អញ្ជើញជាគណៈអធិបតីក្នុងពិធីអបអរសាទរទិវាជាតិ និងអន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ០៩ធ្នូ នៅសាលសហព័ន្ធកីឡាការ៉ាតេកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

+សមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ "រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព" នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ

+សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ខួបលើកទី៧៤ ឆ្នាំ២០២២ ក្រោមប្រធានបទ "ខួបលើកទី៧៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" រៀបចំឡើងដោយគណៈកម្មការទី១ព្រឹទ្ធសភា សហការជាមួយគណៈកម្មការទី១រដ្ឋសភា អង្គការការីតាសកម្ពុជា និងក្រុមហ៊ុនសាប៊ូក្វិន នៅវិមានព្រឹទ្ធសភា

+សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អាណត្តិទី៥ ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ភោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេស ពិនិត្យដំណើរការចុះឈ្មោះបោះឆ្នោតនៅតាមមូលដ្ឋានរៀងៗខ្លួនក្នុងភូមិភាគទាំង៨ ចំនួន៧៥លើក

-បានរៀបចំវេទិកាស្តីពី ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ជាស្ត្រីក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅខេត្តសៀមរាប

-បានផ្តល់សេវាជូនឯកឧត្តម **លី ឡេង** នាយកខុទ្ទកាល័យ ជាតំណាង**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា** រួមជាមួយមន្ត្រីខុទ្ទកាល័យ អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃការកសាងកំផែងវត្ត ស្ថិតក្នុងវត្តពង្រវង្សី ស្រុកកញ្ច្រៀច ខេត្តព្រៃវែង

-បានផ្តល់សេវាជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សហការជាមួយក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា** ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃបេសកកម្មមនុស្សធម៌(AMH)នៃសាធារណរដ្ឋបារាំង នៅកម្ពុជា ចុះពិនិត្យ និងព្យាបាលជំងឺ ដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ នៅខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់

-បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រចំនួន៤៥នាក់

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៣៨នាក់

-បានផ្តល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនមជ្ឈមណ្ឌលបណ្តុះ-បណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ និងពុទ្ធិកសាកលវិទ្យាល័យចំនួន២៤២ក្បាល

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែធ្នូ ឆ្នាំ២០២២ ចំនួន៨០០ក្បាល

-បានធ្វើបច្ចុប្បន្នភាព និងផលិតសៀវភៅបត់ស្តីពី ព្រឹទ្ធសភា នីតិកាលទី៤ (ភាសាខ្មែរ អង់គ្លេស និងភាសាបារាំង) ចំនួន៣,០០០សន្លឹក

-បានបោះពុម្ពទិនានុលេខន៍ ប្រតិទិន ប័ណ្ណរថយន្តសម្រាប់ឆ្នាំ២០២៣

-បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលសម្តេចទទួលបានពានរង្វាន់ "សមិទ្ធផលពេញមួយជីវិតរបស់មេដឹកនាំឆ្នើម" ពីវិទ្យាស្ថានយុទ្ធសាស្ត្រសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក(KSI) និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទ-ក្រហមកម្ពុជា ក្នុងឱកាសចម្រើនជន្មាយុ

-បានរៀបចំសារលិខិតថ្វាយព្រះពរទូលថ្វាយព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** និងជូនពរ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី, ថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា, ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងឥស្សរជនជាន់ខ្ពស់តាមក្រសួងស្ថាប័ននានា ក្នុងឱកាសចូលឆ្នាំសកលឆ្នាំ២០២៣

-បានចាត់ចែងបញ្ជូនសារលិខិតអបអរសាទរ និងថ្លែងអំណរគុណរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់ចំនួន០៥លិខិត

-បានរៀបចំ និងផ្ញើសាររំលែកទុក្ខក្នុងនាមថ្នាក់ដឹកនាំ និងគណៈប្រតិភូព្រឹទ្ធសភាចំនួន០៦លិខិត និងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធរបស់ឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន០៥លើក

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៩ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីក្រសួងការពារជាតិចំនួន០១ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៧ករណី។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា៖**

+ ក្នុងពិធីជំនួបសម្តែងការគួរសម និងសន្ទនាការជាមួយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង(APF)

+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធឯកឧត្តម **ជាំង ជឺមិន** អតីតប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន នៅស្ថានឯកអគ្គរដ្ឋទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជូនសមាជិកព្រឹទ្ធសភា ជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន, គណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រើភាសាបារាំង(APF), និងប្រធានសម្ព័ន្ធសភាកូរ៉េ

- បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចការងារ និងចូលរួមកិច្ចប្រជុំក្រុមមិត្តភាពនៃសភាប្រទេសទាំងពីរកម្ពុជា-វៀតណាម ព្រមទាំងកិច្ចប្រជុំលើកទី១០ នៃសភាប្រើភាសាបារាំង(APF) តំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានរៀបចំជូនប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីសភានៃព្រះរាជាណាចក្រថៃឡង់ដ៍ និងព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង

- ឯកឧត្តម ***អ៊ុំ សារិទ្ធ*** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក Gilbert Palaoro អតីតទទួលបន្ទុកទីភ្នាក់ងារឧត្តមសិក្សានៃសាកលវិទ្យាល័យប្រើភាសាបារាំង ចូលជួបសម្តែងការគួរសម និងថ្លែងអំណរគុណ

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ស្តីពី កម្មវិធីកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ជាមួយវិទ្យាស្ថានស្រាវជ្រាវ KING PRAJADHIPOK INSTITUTION (KPI) នៃព្រះរាជាណាចក្រថៃឡង់ដ៍

-បានរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសរបស់គណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រើភាសាបារាំង(APF) ជូនឯកឧត្តមប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា

- បានរៀបចំសិក្ខាសាលាស្តីពី "កម្ពុជា-ចិន រួមជោគវាសនាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩" និងពិធីប្រគល់-ទទួលអំណោយឧបករណ៍តេស្តរហ័សកូវីដ-១៩ នៅសាលប្រជុំបណ្ណាល័យព្រឹទ្ធសភា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតសិង្ហបុរី, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការសហប្រជាជាតិនៅកម្ពុជា,

អង្គការតម្លាភាពកម្ពុជា(TI Cambodia), មូលនិធិសន្តិភាពដើម្បីអភិវឌ្ឍ, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), សាលាភូមិន្ទរដ្ឋបាល, មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានSunrise, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានGreatX Center, វិទ្យាស្ថានSalaCyber, វិទ្យាស្ថានMUT International College, វិទ្យាស្ថានខុងជឺ, ភ្នាក់ងារសព្ទមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, បណ្ណាល័យអាស៊ី-អឺរ៉ុប និងបណ្ណាល័យជាតិ, ក្រុមហ៊ុនKOHA, ក្រុមហ៊ុន Cambodia Hosting, ក្រុមហ៊ុន Huawei និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បានប្រជុំក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំការងារជាមួយអង្គភាពកិច្ចការសង្គម ដើម្បីពិនិត្យការអនុវត្តការងារ តួនាទី ភារកិច្ចរបស់អង្គភាពកិច្ចការសង្គម

-បានប្រជុំគណៈកម្មការពិនិត្យវាយតម្លៃសមត្ថភាពមន្ត្រីរាជការ ដើម្បីតែងតាំងមុខតំណែងក្នុងអង្គការលេខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំត្រួតពិនិត្យពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំបូកសរុបលទ្ធផលការងាររបស់សមាគមសង្គហៈមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖**

-បានបើកប្រាក់បៀវត្សប្រចាំខែធ្នូ ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបោះផ្សាយអាណត្តិឥណទានបន្ថែមជំពូក៦១ សម្រាប់ចំណាយបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានរៀបចំរបាយការណ៍សមិទ្ធកម្មត្រីមាសទី៤ ឆ្នាំ២០២២ និងផែនការសកម្មភាពដំណាក់កាលទី៤ (MAP4)ឆ្នាំ២០២៣ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានតាមដានគោលការណ៍ និងព័ត៌មានថ្មីទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងកំណត់បង្ហាញចំនួន០៦ច្បាប់

- បានធ្វើប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០២ប័ណ្ណ

- បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន៥៥នាក់ និងក្រៅប្រទេសចំនួន០១វគ្គ មានសិក្ខាកាមចូលរួមចំនួន០១នាក់ ព្រមទាំងសិក្ខាសាលាក្នុងប្រទេសចំនួន០២លើក មានសិក្ខាកាមចូលរួមចំនួន២៦០នាក់

- បានរៀបចំពិធីបាឋកថាស្តីពី ការឈ្វេងយល់ពីវិជ្ជាពេទ្យបុរាណចិន នៅសាលប្រជុំបណ្ណាល័យព្រឹទ្ធសភា

- បានធ្វើរបាយការណ៍វាយតម្លៃការធ្វើបទបង្ហាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃវគ្គបណ្តុះបណ្តាលស្តីពី "កិច្ចការសភា ជំហានទី៦" និង "ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ" ចំនួន៥២លើក

- បានទទួលលិខិតចូលចំនួន៣៣៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៨០ច្បាប់

- បានបាញ់ថ្នាំសម្លាប់មេរោគ និងថ្នាំសម្លាប់សត្វល្អិតនៅក្នុងបរិវេណព្រឹទ្ធសភាចំនួន០៦លើក

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៧លើក

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុលកែលម្អៈ ខាត់ និងលាបជញ្ជាំងផ្នែកខាងក្នុង-ក្រៅអគារខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា អគារបណ្ណាល័យ និងបន្ទប់សារព័ត៌មានក្រោមអគារក្រហម, ប្តូរកែងអូតូទ្វារដែកនៅអគ្គាធិការ និងអង្គភាពលទ្ធកម្ម ព្រមទាំងស្តារប្រព័ន្ធលូ និងលាងបំពង់បង្ហូរទឹកភ្លៀងនៅជុំវិញអគារក្រហម

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២០៨គ្រឿង/លើក

- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោង

រដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៤៤លើក

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

- បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២។

**៥.២-ការងារសេវាច្បាប់៖**

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរដ្ឋសភា

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗចំនួន២៩៨ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៥ច្បាប់

- បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

**៥.៣-ការងារស្រាវជ្រាវ៖**

- បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានសិក្សាស្រាវជ្រាវ ចងក្រង និងផលិតឯកសារលើប្រធានបទចំនួន១៤ប្រធានបទ

- បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥)

- បានផលិត និងផ្សាយព្រឹត្តិបត្រស្រាវជ្រាវសេដ្ឋកិច្ច សង្គម ស្តីពី វិបត្តិថាមពលសកលឆ្នាំ២០២២

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៩៧អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែធ្នូ ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

**៥.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន០២លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលកុំព្យូទ័រ និងដាក់កម្មវិធី

កម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន១៤៣គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន១១០ប្រធានបទ

- បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២គ្រឿង

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១៩៩ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្នី និងសងសៀវភៅចំនួន៣០២ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៣១លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៤លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន១,១១៦ប្រធានបទ

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿនល្អ និងរលូន។

**៤.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៨លើក

- បានរៀបចំ និងបញ្ជូនសារលិខិតថ្លែងអំណរគុណ លិខិតអបអរសាទរ និងរំលែកទុក្ខរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់នៃបណ្តាប្រទេសជាមិត្តចំនួន០៧លិខិត

- បានកសាងសុន្ទរកថា និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន២១លិខិត

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំឆ្នាំ២០២២ ចំនួន០១ច្បាប់។

**៤.៦-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២២ ចំនួន១៩លើក

- បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ

និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន២២លើក ប្រចាំសប្តាហ៍ចំនួន០៤លើក និងប្រចាំខែធ្នូ ឆ្នាំ២០២២

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែធ្នូ ឆ្នាំ២០២២។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២២ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥ច្បាប់ ស្មើនឹង១៥០នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៧ច្បាប់ ស្មើនឹង០៧នាក់

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣៧២លើក

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៩៨សំណើ

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៥លើក មានអ្នកចូលរួមចំនួន១,៥៦៣នាក់

-បានថតចម្លងឯកសារចំនួន៦,៨៨៣ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៦៣ក្បាល អស់ក្រដាសចំនួន១០២,៩៦៨សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១៣២លើក ស្មើនឹង៥១៨នាក់

-បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ និងចងបដា ពាក្យស្លោកចំនួន០៩លើក

-បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន១៩លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន ៣២៩លើក

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន២៥លើក។

**II-ទិសដៅការងារខែមករា ឆ្នាំ២០២៣**

-ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ

-បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេក-វិទ្យាព័ត៌មាន

-បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ**

+ធានាប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

+ទ្រទ្រង់ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិកព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល (ចាប់ពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣)

+បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ក្រុម និងគណៈកម្មការនានា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និង តាមបណ្តាខេត្ត ក្រុងនានា ក្នុងអំឡុងពេលវិស្សមកាល។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចូលរួមទិវាជ័យជម្នះ៧មករា លើរបបប្រល័យ ពូជសាសន៍

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយ ប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងទី៦ ចុះជួបសំណេះសំណាលជាមួយ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអគ្គទូតនានា នៃប្រទេសជាមិត្ត

-ត្រៀមរៀបចំជំនួបសម្តែងការគួរសមជាមួយឯកអគ្គរាជទូតនៃព្រះរាជាណាចក្រថៃឡង់ដ៍ និងគណៈប្រតិភូសភាកូរ៉េ

-ត្រៀមរៀបចំជំនួបជាមួយបេក្ខជន បេក្ខនារីជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលនូវែលសេឡង់ (ឆ្នាំសិក្សា២០២៣-២០២៤)

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយ

ដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង-ក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត (PCA, AVI) និងដៃគូផ្សេងៗទៀតៗ

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៩ និងលើកទី១០ នីតិកាលទី៤

-គ្រប់អង្គភាពពាក់ព័ន្ធត្រៀមធ្វើរបាយការណ៍តាមវិស័យ និងរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំឱ្យបានល្អ និងទាន់ពេលវេលា

-ត្រៀមរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ និងការបែងចែកឥណទានឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមរៀបចំបោះអាណត្តិសម្រាប់ឆ្នាំ២០២៣

-បន្តតាមដានជាមួយស្ថានទូតចិន ស្ថានទូតវៀតណាម ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មចិនប្រចាំព្រះរាជាណាចក្រកម្ពុជា គម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែមករា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំបែបបទដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៣

-ការតែងតាំងមុខតំណែងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តវិចារណកម្មថវិកា៖ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ច របស់នាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មី ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែងចំនួន០៣គឺ៖

១-គោលការណ៍ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម
២-គោលការណ៍ស្តីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ
៣-គោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្ស

-គិតគូររៀបចំដំឡើងបៀវត្សតាមឋានន្តរសក្តិ និងថ្នាក់ជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០២៣

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ធ្វើសម្រង់តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការប្រចាំឆ្នាំ២០២៣

-កសាងផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៣

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-បន្តសិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី និងប្លង់សាងសង់របងថ្មីខាងមុខព្រឹទ្ធសភា

-បន្តការងារជួសជុលថែទាំអគារ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា អគារបណ្ណាល័យ គូសគំនូសចរាចរ ចំណតយានយន្ត និងជួសជុលផ្លាស់ប្តូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

-កែលម្អបរិស្ថាន និងអនុវត្តការងារជួសជុលផ្សេងៗក្នុងករណីចាំបាច់ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់អនាម័យ និងវិន័យការងារ

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្តើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងបំពាក់សម្ភារៈ

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត (ឥណ្ឌា...)

-ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## IV-**សេចក្តីសន្និដ្ឋាន**

ខែធ្នូនេះ ជាខែចុងក្រោយនៃឆ្នាំ២០២២ ទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់គ្រប់ការដ្ឋាន ដើម្បីបិទបញ្ចប់ការងារស្របតាមផែនការប្រតិបត្តិដែលបានកំណត់នៅក្នុងឆ្នាំ២០២២ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងបានរៀបចំផែនការប្រតិបត្តិសម្រាប់ឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំផ្តល់សេវាបានយ៉ាងល្អប្រសើរ ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក។ ជាពិសេសបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈ-កម្មការជំនាញទាំង១០ ក្នុងរយៈពេលវិស្សមកាល ដើម្បីចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយក្រសួង ស្ថាប័ននានា រៀបចំវេទិកា ព្រមទាំងផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ចុះជួបសំណេះ-សំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន សម្កោធសមិទ្ធផល ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និង

បញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំចាត់ចែងយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំនានាប្រព្រឹត្តទៅដោយរលូន និងបានទទួលឧបករណ៍តេស្តកូវីដ-១៩ ដែលជាអំណោយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនដល់ព្រឹទ្ធសភាកម្ពុជា។

មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃចន្ទ ១១កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**